**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**តុលាការរដ្ឋប្បវេណី**

-សំណុំរឿងរដ្ឋប្បវេណីលេខ ២៥៩
ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២
-សាលក្រមរដ្ឋប្បវេណីលេខៈ ០៦"ង"/០៩
ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈនៅសាលសវនាការលេខ(ក២)នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ វេលារសៀល។

**ចៅក្រម**

-លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជី**

-លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

-ដើមចោទឈ្មោះ [redacted] ស្រីតូច ភេទស្រី កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៣ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ១៨០៧៦១២៣២ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ អាសយដ្ឋាន [redacted]

មេធាវីតំណាងដោយអាណត្តិ លោក [redacted] មានការិយាល័យនៅ [redacted]

-ចុងចម្លើយឈ្មោះ [redacted] ប៉ានី ភេទប្រុស កើតថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៨២ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ១៨០៤៥៣៧១០(០១) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ អាសយដ្ឋានបច្ចុប្បន្ន[redacted]។

## I. អង្គហេតុ និងចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

ក.ដើមចោទឈ្មោះ [redacted] ស្រីតូច លែងលះពីចុងចម្លើយឈ្មោះ [redacted] ប៉ានី។

ខ.ដើមចោទឈ្មោះ [redacted] ស្រីតូច សុំមានអំណាចមេបាលើកូនចំនួន០១នាក់ ឈ្មោះ [redacted] ប៉ានុតថៃ ភេទប្រុស កើតថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤។

គ.ចុងចម្លើយឈ្មោះ [redacted] ប៉ានី បង់ប្រាក់បន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រង ថែរក្សាកូនឈ្មោះ [redacted] ប៉ានុតថៃ ក្នុង១ខែ ចំនួន២០០.០០០(ម្ភៃម៉ឺន)រៀល។

ឃ.ដើមចោទឈ្មោះ [redacted] ស្រីតូច អ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី។

២.ការពន្យល់ត្រួសៗអំពីរឿងក្ដី

រឿងក្ដីនេះ គឺជារឿងក្ដីដែលដើមចោទឈ្មោះ [redacted] ស្រីតូច និងចុងចម្លើយឈ្មោះ [redacted] ប៉ានី បានរៀបការជាមួយគ្នាកាលពីឆ្នាំ២០១២ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ១៥ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១២ ចុះថ្ងៃទី២២ ខែ



Scanned with CamScanner

មីនា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ក្នុងចំណងអាពាហ៍ពិពាហ៍ រវាងដើមចោទ និងចុងចម្លើយ មានកូនចំនួន០១នាក់ ឈ្មោះ **ហឿន វ៉ានុតថៃ** ភេទប្រុស កើតថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ ហើយពុំមានទ្រព្យសម្បត្តិរួមពាក់ព័ន្ធទេ។ ដើមចោទបានដាក់ពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ លែងលះពីចុងចម្លើយ ដោយមូលហេតុរស់នៅមិនចុះសម្រុងគ្នា ចាប់តាំងពីឆ្នាំ២០២១ មកគឺចុងចម្លើយ រករឿងឈ្លោះប្រច័ណ្ឌ អារម្មណ៍ឆេវឆាវ ស្រែកជេរប្រមាថ ប្រើពាក្យសំដីគំរាមកំហែង ចិត្តចង្អៀតមិនឱ្យដើមចោទចូលរួមក្នុងការងារសង្គម កន្លងមកនេះចុងចម្លើយតែងប្រើពាក្យសំដីអសុរស និង ប្រើហិង្សាលើដើមចោទជាញឹកញាប់ ចុងចម្លើយធ្លាប់ធ្វើកិច្ចសន្យាកែខ្លួន មានការណែនាំ អប់រំ ពីអាជ្ញាធរមូលដ្ឋានឃុំ ដោយសុំសម្រួលជាមួយដើមចោទជាច្រើនលើក តែចុងចម្លើយមិនព្រមកែខ្លួន ដើមចោទមានការបារម្ភពីសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងជាពិសេសអាចនឹងបង្កហិង្សាក្នុងគ្រួសារកាន់តែធ្ងន់ធ្ងរនៅពេលខាងមុខ ទើបដើមចោទបានចាកចេញពីចុងចម្លើយទៅរស់នៅបែកលំនៅផ្សេងគ្នារហូតមកទល់បច្ចុប្បន្ន ជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាពីចុងចម្លើយ។

### ៣. ចំណុចដែលមានវិវាទ និងចំណុចដែលគ្មានវិវាទ

#### ៣.១.ចំណុចដែលគ្មានវិវាទ:

ក-ដើមចោទឈ្មោះ [redacted] ស្រីតូច និង ចុងចម្លើយឈ្មោះ [redacted] វ៉ានី ឯកភាពលែងលះ។

ខ-ដើមចោទឈ្មោះ [redacted] ស្រីតូច ទាមទារប្រាក់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹម បីបាច់ថែរក្សាកូន ក្នុងមួយខែចំនួន២០០.០០០(ម្ភៃម៉ឺន)រៀល រហូតកូនពេញវ័យនីតិភាព ចុងចម្លើយឈ្មោះ [redacted] វ៉ានី ឯកភាព។

#### ៣.២.ចំណុចដែលមានវិវាទ:

គ-ដើមចោទឈ្មោះ [redacted] ស្រីតូច សុំមានអំណាចមេបាលើកូនចំនួន០១នាក់គឺឈ្មោះ [redacted] វ៉ានុតថៃ ភេទប្រុស ចុងចម្លើយឈ្មោះ [redacted] វ៉ានី មិនឯកភាព។

### ៤. ការអះអាងរបស់គូភាគី

#### ៤.១. ការអះអាងរបស់ភាគីដើមចោទ

៤.១.១.ដើមចោទឈ្មោះ [redacted] ស្រីតូច មានមេធាវីតំណាងដោយអាណត្តិ លោក [redacted] បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: កាលពីឆ្នាំ២០១២ ខ្លួន និងចុងចម្លើយ បានរៀបការតាមប្រពៃណីខ្មែរ រស់នៅជាប្តីប្រពន្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដូចមានក្នុងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ សំបុត្រអាពាហ៍ពិពាហ៍លេខ១៥ សៀវភៅអាពាហ៍ពិពាហ៍លេខ០១/២០១២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ខ្លួនសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] វ៉ានី ដោយមូលហេតុរស់នៅមិនចុះសម្រុងគ្នា រយៈពេល២ឆ្នាំចុងក្រោយ ចុងចម្លើយប្រើហិង្សាផ្លូវកាយ ផ្លូវចិត្តលើរូបខ្លួន រករឿងឈ្លោះប្រច័ណ្ឌ អារម្មណ៍ឆេវឆាវ ស្រែកជេរប្រមាថ ប្រើពាក្យសំដីគំរាមកំហែង ចិត្តចង្អៀតមិនឱ្យខ្លួនចូលរួមការងារសង្គម និងធ្លាប់មានធ្វើកិច្ចសន្យាកែខ្លួននៅសាលាឃុំកណ្តែក តែមិនព្រមកែតាមកិច្ចសន្យា ជាមូលហេតុធ្វើឱ្យខ្លួនអស់ជំនឿចិត្ត អស់មនោសញ្ចេតនា មិនអាចបន្តការរួមរស់ជាប្តីប្រពន្ធតទៅបាន ហើយខ្លួនបានចាកចេញពីចុងចម្លើយទៅរស់នៅផ្ទះជួល តាំងពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ រហូតមកទល់បច្ចុប្បន្ន។



Scanned with CamScanner

ខ្លួន និងចុងចម្លើយ រួមរស់ក្នុងចំណងអាពាហ៍ពិពាហ៍មានកូននឹងគ្នា ចំនួន១នាក់ឈ្មោះ [redacted] រ៉ានុតថៃ ភេទប្រុស កើតថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ មានសេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ សំបុត្រកំណើតលេខ៧៩ សៀវភៅកំណើតលេខ០២/២០១៤ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ខ្លួនសុំមានសិទ្ធិអំណាចមេបាលើកូន១នាក់ខាងលើ ដោយមូលហេតុ ពីមុនកូនរស់នៅជាមួយខ្លួន ក្រោយខ្លួនចាកចេញពីចុងចម្លើយកូនរស់នៅជាមួយចុងចម្លើយរហូតមកដោយសារកូនត្រូវនៅរៀន តែខ្លួនជាម្តាយស្រឡាញ់កូន យកចិត្តទុកដាក់នឹងកូន អាចមើលថែកូនបាន មានមុខរបររត់តុ បានកម្រៃក្នុងមួយខែចំនួន១៤០ដុល្លារអាមេរិក ចំណូលនេះគ្រប់គ្រាន់សម្រាប់ចិញ្ចឹមកូន និងមានផ្ទះឱ្យកូនរស់នៅសមរម្យ។ បើកូនរស់ជាមួយខ្លួន គឺខ្លួនមានពេលមើលកូនបាន ដោយសារខ្លួនធ្វើការពេលយប់ ហើយមានឪពុកម្តាយរបស់ខ្លួនមានផ្ទះនៅជាប់ព្រំដីគ្នាអាចជួយមើលថែកូនរបស់ខ្លួនបានថែមទៀតផង។ ខ្លួនសុំឱ្យចុងចម្លើយឈ្មោះ [redacted] រ៉ានី បង់ប្រាក់បន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រង ថែរក្សាកូន ក្នុង១ខែចំនួន២០០.០០០(ម្ភៃម៉ឺន)រៀល រហូតកូនមានវ័យនីតិភាព។ តែបើចុងចម្លើយសុំមានអំណាចមេបាលើកូននេះដែរ ខ្លួនសុំឱ្យតុលាការសួរលើចិត្តកូន បើកូនសុខចិត្តទៅរស់នៅខាងចុងចម្លើយខ្លួនមិនជំទាស់ទេ តែខ្លួនសំណូមពរសុំឱ្យចុងចម្លើយផ្តល់សិទ្ធិឱ្យកូនបានមកលេង និងជួបសួរសុខទុក្ខជាមួយខ្លួនផង។ ខ្លួន និងចុងចម្លើយ ពុំមានទ្រព្យសម្បត្តិរួមពាក់ព័ន្ធទេ តែមានបំណុលរួមជំពាក់ធនាគារចំនួន៣១០០ដុល្លារអាមេរិក ខ្លួនពុំទាមទារឱ្យចុងចម្លើយទទួលខុសត្រូវសងទេ ខ្លួនអ្នកទទួលខុសត្រូវសងម្នាក់ឯង ព្រោះខ្លួនបានយកដីកេរ៍ខាងខ្លួនទៅដាក់បញ្ចាំលើបំណុលខាងលើ។ ការទាមទារខាងលើបានដាក់កស្តុតាងជូនតុលាការពិនិត្យដោយភ្ជាប់មកជាមួយពាក្យបណ្តឹង និងគ្មានអ្វីផ្សេងដាក់ជូនបន្ថែមទេ។

៤.១.២.ដើមចោទឈ្មោះ [redacted] ស្រីតូច បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា: ខ្លួនសូមរក្សានូវសេចក្តីថ្លែងការណ៍ដែលខ្លួនបានថ្លែងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដដែល ពុំមានអ្វីកែប្រែ ឬបន្ថែមទៀតនោះទេ និងសុំឱ្យតុលាការសម្រេចតាមការទាមទាររបស់ខ្លួនដោយក្តីអនុគ្រោះ។ ចំពោះកូនប្រុសឈ្មោះ [redacted] រ៉ានុតថៃ រស់នៅជាមួយចុងចម្លើយនៅនឹងផ្ទះដីរបស់ខ្លួន។ ខ្លួន និងចុងចម្លើយបានរស់នៅបែកគ្នា ចាប់ពីខែមីនា ឆ្នាំ២០២២ រហូតមក ពេលនេះពុំមានលក្ខខ័ណ្ឌឱ្យចុងចម្លើយកែខ្លួនទេ អស់ភាពអត់ធ្មត់ក្នុងការរស់នៅជាមួយចុងចម្លើយ។ ខ្លួនសំណូមពរថា ឱ្យចុងចម្លើយយកកូនទៅលេងបាន តែមិនឱ្យយកកូនទៅដាច់យប់ទេ ត្រូវយកកូនមកប្រគល់ឱ្យខ្លួនវិញ និងពេលសាលាដំបូងសម្រេចសេចក្តី ខ្លួនសុំទៅរស់នៅនឹងផ្ទះរបស់ខ្លួនជាមួយកូន ត្បិតផ្ទះនេះសង់នៅលើដីកេរ៍ខាងខ្លួន សព្វថ្ងៃចុងចម្លើយកំពុងរស់នៅនឹងផ្ទះនេះ។

លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា: រឿងក្តីនេះពាក់ព័ន្ធនឹងឋានៈបុគ្គល ជាមនោសញ្ចេតនាផ្ទាល់របស់ដើមចោទអ្នកសម្រេចចិត្តលើបណ្តឹងសុំលែងលះរបស់ខ្លួន ហើយខ្លួនគ្រាន់តែសូមសំណូមពរស្នើសុំឱ្យសម្រេចតាមការទាមទាររបស់ដើមចោទ។

៤.២. ការអះអាងរបស់ភាគីចុងចម្លើយ

៤.២.១.ចុងចម្លើយឈ្មោះ [redacted] រ៉ានី បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្លួនទទួលស្គាល់អង្គហេតុ កាលពីឆ្នាំ២០១២ ខ្លួន និងដើមចោទបានរៀបការរួមរស់ជាប្តីប្រពន្ធរហូតមក និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ រួមរស់ក្នុងចំណង



Scanned with CamScanner

អាពាហ៍ពិពាហ៍មានកូនចំនួន០១នាក់ជាមួយគ្នា និងពុំមានទ្រព្យសម្បត្តិរួមពាក់ព័ន្ធជាមួយគ្នាដូច ដើមចោទបានអះអាងបង្ហាញភស្តុតាងខាងលើមែន។ ហើយការសុំលែងលះខ្លួនក៏ឯកភាពដែរ ដោយ មិនអាចត្រឡប់មកសះជានឹងគ្នាវិញបាន តែការដែលខ្លួនខឹង គឺខ្លួនមានចិត្តឆេវឆាវប្រើសំដីធ្ងន់បន្តិច មែន តែអត់ដែលប្រើអំពើហិង្សាទៅលើដើមចោទទេ ធ្លាប់វាយមួយដៃដោយដើមចោទប្រើសំដីពាក្យ អាមឹងមករកខ្លួនដែរ ហើយខ្លួនធ្លាប់បានធ្វើកិច្ចសន្យាកែខ្លួននៅសាលាឃុំកណ្តែក រួចរាល់ហើយដែរ។ បន្ទាប់មកខ្លួនមិនដែលធ្វើឱ្យខុសនឹងកិច្ចសន្យានោះទេ ក្រោយធ្វើកិច្ចសន្យាបានមួយរយៈ នៅថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២២ ដើមចោទក៏បានចាកចេញពីខ្លួនគ្មានដំណឹង ខ្លួនបានទៅប្តឹងពីការបាត់ខ្លួន នៅប៉ុស្តិ៍ឃុំកណ្តែក ហើយការអះអាងរបស់ដើមចោទលើចំណុចមួយចំនួនដែលថាខ្លួនប្រើហិង្សាលើ ផ្លូវកាយ ផ្លូវចិត្ត ខ្លួនមិនអាចទទួលយកបានទេព្រោះមិនត្រឹមត្រូវ។ រីឯកូនចំនួន១នាក់ខាងលើពិតជា កូន រវាងខ្លួនជាមួយដើមចោទ ចំពោះដើមចោទសុំអំណាចមេបាលើកូន០១នាក់ខាងលើ ខ្លួនមិន យល់ព្រមឱ្យដើមចោទមានអំណាចមេបាលើកូនទេ និងមិនបង់ប្រាក់សោហ៊ុយចាំបាច់ ថែរក្សាកូន ឱ្យទៅដើមចោទឡើយ និង សុំឱ្យសួរចិត្តកូនថាចង់រស់នៅជាមួយដើមចោទ ឬក៏ខ្លួន ដោយសារកូន រស់នៅជាមួយខ្លួនតាំងពីកើតរហូតដល់ពេលនេះ ខ្លួនក៏ស្រឡាញ់កូន ផ្តល់ភាពកក់ក្តៅឱ្យកូនបាន មានរបរជាអ្នកដឹកទឹកបរិសុទ្ធតាមរ៉ឺម៉កដាក់ឱ្យតាមតូបលក់ដូរ មានចំណូលក្នុងមួយថ្ងៃបានកម្រៃពី ចំនួន៣០.០០០រៀល ទៅចំនួន៤០.០០០រៀល អាចចិញ្ចឹមកូនបាន និងមានផ្ទះរស់នៅសមរម្យ។ សព្វថ្ងៃកូនកំពុងរស់នៅជាមួយខ្លួន ហើយពេលខ្លះឪពុកក្មេកខ្លួនជាអ្នកជូនកូនខ្លួនទៅរៀន និងពេល ខ្លះឪពុកក្មេកជាប់រវល់ខ្លួនអ្នកជូនកូនទៅរៀនដោយផ្ទាល់ខ្លួនឯង។ កូនរស់នៅជាមួយខ្លួន គឺមានខ្លួន អ្នកមើលថែដោយផ្ទាល់ បើខ្លួនរវល់ខ្លាំង ឪពុកម្តាយក្មេករបស់ខ្លួនជួយមើលថែ។ តែបើតុលាការ សម្រេចប្រគល់កូនឱ្យដើមចោទគ្រប់គ្រងនោះខ្លួនក៏យល់ព្រម និងសុខចិត្តបង់ប្រាក់សោហ៊ុយចាំបាច់ ថែរក្សាកូន ក្នុងមួយខែ ចំនួន២០០.០០០(ម្ភៃម៉ឺន)រៀល ឱ្យទៅដើមចោទ។

៤.២.២.ចុងចម្លើយឈ្មោះ [redacted] រ៉ានី បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផល ដោយផ្ទាល់មាត់ថា: ខ្លួនសូមរក្សានូវសេចក្តីថ្លែងការណ៍ដែលខ្លួនបានថ្លែងនៅក្នុងនីតិវិធីត្រៀមសម្រាប់ ការទាញហេតុផលដដែល សុំកែប្រែដោយសុខចិត្តឱ្យដើមចោទមានអំណាចមេបាលើកូន ដោយមូល ហេតុដើមចោទជាម្តាយផ្តល់ភាពកក់ក្តៅដល់កូន មានពេលគ្រប់គ្រាន់មើលថែកូនបានល្អជាងខ្លួន។ ខ្លួនសុំជួយចិញ្ចឹមកូនតាមលទ្ធភាព ព្រោះខ្លួនខ្លាចរកលុយអត់បាន បើខែខ្លះខ្វះខាតខ្លាចអត់មាន លុយឱ្យ ពេលនេះខ្លួនមានលទ្ធភាព ក្នុងមួយខែ បង់ចំនួន២០០.០០០(ម្ភៃម៉ឺន)រៀល ខ្លួនបង់ឱ្យ បាន តែខ្លួនសំណូមពរទៅខាងដើមចោទឱ្យមើលថែកូនឱ្យបានល្អ ចំពោះដី ផ្ទះ ខ្លួនមិនទាមទារទេ។

៥. ការសាកសួរសាក្សី

សាក្សីឈ្មោះ [redacted] រ៉ានុតធៃ ភេទប្រុស កើតថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ ដែលជាកូនរបស់ ដើមចោទ និងចុងចម្លើយ បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា: រាល់ថ្ងៃខ្លួនរស់នៅជាមួយប៉ា បើប៉ាម៉ាក់នៅផ្ទះផ្សេងគ្នា ខ្លួនសុំទៅរស់នៅខាងម៉ាក់។

## II. ការពិនិត្យភស្តុតាង

កស្តុតាងជាឯកសាររបស់ដើមចោទ ៖

១-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ ចេញដោយមន្ត្រី រក្សាសៀវភៅស្រុកប្រាសាទបាគង។



Scanned with CamScanner

២-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ១៨០៤៥៣៧១០(០១) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០១៥។

៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ១៨០៧៦១២៣២ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤។

៤-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ចេញដោយមន្ត្រីរក្សាសៀវភៅស្រុកប្រាសាទបាគង។

៥-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ត្រីរក្សាសៀវភៅស្រុកប្រាសាទបាគង។

៦-សេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ចេញដោយមន្ត្រីរក្សាសៀវភៅស្រុកប្រាសាទបាគង។

៧-បង្កាន់ដៃ បញ្ជាក់លេខក្បាលដី ១៧១៨ នៅភូមិល្អក់ ម្ចាស់ដីឈ្មោះ [redacted] រ៉ានី និង ឈ្មោះ [redacted] ស្រីតូច ទ្រព្យខាងប្រពន្ធ ជាក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដី សំរាប់ផ្ទៀងផ្ទាត់ទីតាំងដី និងព្រំប្រទល់របស់ម្ចាស់ដី លេខ៧០៤៦១២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

**១.ស្តីអំពី ការទាមទារលែងលះ៖**

១.១.តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ១៥ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ព្រមទាំងការអះអាងរបស់ដើមចោទ ដែលបានអះអាងថា នៅឆ្នាំ២០១២ ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍រួមរស់ជាប្តីប្រពន្ធ និង បានចុះសំបុត្រអាពាហ៍ ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដូចមាននៅក្នុងសំបុត្រអាពាហ៍ពិពាហ៍លេខ១៥ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប នោះ គឺអាចឱ្យតុលាការជឿបានថា ដើមចោទ និង ចុងចម្លើយពិតជាបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ពិតប្រាកដមែន។ ការដែលដើមចោទ និងចុងចម្លើយរស់នៅជាមួយគ្នាដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នឹងគ្នាបែបនេះ គឺមានន័យថាដើមចោទ និងចុងចម្លើយ មានជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា គឺរស់នៅជាមួយគ្នាមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

១.២.ដើមចោទបានអះអាងថា ខ្លួនសុំលែងលះជាមួយចុងចម្លើយ ដោយមូលហេតុរស់នៅមិនចុះសម្រុងគ្នា រយៈពេល២ឆ្នាំចុងក្រោយ ចុងចម្លើយប្រើហិង្សាផ្លូវកាយ ផ្លូវចិត្តលើរូបខ្លួន រករឿងឈ្លោះប្រច័ណ្ឌ អារម្មណ៍ឆេវឆាវ ស្រែកជេរប្រមាថ ប្រើពាក្យសំដីគំរាមកំហែង ចិត្តចង្អៀតមិនឱ្យខ្លួនចូលរួមការងារសង្គម ធ្លាប់មានធ្វើកិច្ចសន្យាកែខ្លួននៅសាលាឃុំកណ្តែក តែមិនព្រមកែតាមកិច្ចសន្យាជាមូលហេតុធ្វើឱ្យខ្លួនអស់ជំនឿចិត្ត អស់មនោសញ្ចេតនា មិនអាចបន្តការរួមរស់ជាប្តីប្រពន្ធតទៅបាន ហើយខ្លួនបានចាកចេញពីចុងចម្លើយទៅរស់នៅផ្ទះជួល តាំងពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ រហូតមកទល់បច្ចុប្បន្ន។ ចុងចម្លើយបានអះអាងថា ខ្លួនទទួលស្គាល់អង្គហេតុ ការអះអាងបង្ហាញហេតុផលដូចដើមចោទបានអះអាង តែការអះអាងលើមូលហេតុរបស់ដើមចោទ ខ្លួនមិនអាចទទួលយកបានទេ ព្រោះក្រោយខ្លួនបានចុះកិច្ចសន្យាកែខ្លួននៅកន្លែងប៉ុស្តិ៍រដ្ឋបាលនគរបាលឃុំកណ្តែករួចមក ខ្លួនពុំដែល

ប្រើហិង្សាលើដើមចោទទេ ហើយខ្លួនយល់ព្រមលែងលះតាមការទាមទាររបស់ដើមចោទ ដោយមូលហេតុមិនអាចត្រឡប់មកសះជានឹងគ្នាវិញបាន។ តាមការអះអាង របស់ដើមចោទ និងចុងចម្លើយ គឺធ្វើឱ្យតុលាការជឿថាចំណងអាពាហ៍ពិពាហ៍ រវាងដើមចោទ និងចុងចម្លើយពិតជាត្រូវបានបែកបាក់ដោយមិនសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាននោះទេ។

១.៣.ការដែលចំណងអាពាហ៍ពិពាហ៍ រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ដោយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាននោះ គឺបង្ហាញឱ្យឃើញថា ការទាមទារលែងលះរបស់ដើមចោទ គឺស្របតាមមាត្រា ៩៧៨-ង នៃក្រមរដ្ឋប្បវេណី ដែលគប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នាតាមការស្នើសុំរបស់ដើមចោទ។

**២.ស្តីអំពី ការសុំមានអំណាចមេបាលើកូន៖**

២.១.តាមសំបុត្រកំណើតលេខ ៧៩ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប របស់ឈ្មោះ [redacted] វ៉ានុតផៃ និងតាមការអះអាងរបស់ដើមចោទ ដែលបានអះអាងថា ខ្លួន និងចុងចម្លើយមានកូនចំនួន១នាក់ឈ្មោះ [redacted] វ៉ានុតផៃ ភេទប្រុស កើតថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ គឺអាចឱ្យតុលាការជឿបានថា ក្នុងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយពិតជាមានកូនចំនួន១នាក់ខាងលើនេះ ពិតប្រាកដមែន។

២.២.ដើមចោទសុំមានអំណាចមេបាលើកូន១នាក់ខាងលើ ដោយអះអាងថា ពីមុនកូនរស់នៅជាមួយខ្លួន ក្រោយខ្លួនចាកចេញពីចុងចម្លើយកូនរស់នៅជាមួយចុងចម្លើយរហូតមកដោយសារកូនត្រូវនៅរៀន តែខ្លួនជាម្តាយស្រឡាញ់កូន យកចិត្តទុកដាក់នឹងកូន អាចមើលថែកូនបាន មានមុខរបររត់តុបានកម្រៃ ក្នុងមួយខែ ចំនួន១៤០ដុល្លារអាមេរិក ចំណូលនេះគ្រប់គ្រាន់សម្រាប់ចិញ្ចឹមកូន និងមានផ្ទះឱ្យកូនរស់នៅសមរម្យ បើកូនរស់នៅជាមួយខ្លួន គឺខ្លួនមានពេលមើលកូនបាន ដោយសារខ្លួនធ្វើការពេលយប់ ហើយមានឪពុកម្តាយរបស់ខ្លួន ដែលមានផ្ទះនៅជាប់ព្រំដីគ្នាអាចជួយមើលថែកូនរបស់ខ្លួនបានថែមទៀតផង។ រីឯចុងចម្លើយក៏បានយល់ព្រមឱ្យដើមចោទមានអំណាចមេបាលើកូន១នាក់ខាងលើដែរ ដោយអះអាងថា ដើមចោទជាម្តាយផ្តល់ភាពកក់ក្តៅដល់កូន មានពេលគ្រប់គ្រាន់មើលថែកូនបានល្អជាងខ្លួន។ ការដែលដើមចោទ និងចុងចម្លើយព្រមព្រៀងគ្នាកំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូន១នាក់ខាងលើ ហើយកូនក៏ធ្លាប់រស់នៅជាមួយដើមចោទ និងយល់ព្រមរស់នៅជាមួយដើមចោទផងដែរ ព្រមទាំងដើមចោទអាចមានលទ្ធភាពគ្រប់គ្រាន់ដើម្បីចិញ្ចឹមកូនឱ្យរៀនសូត្របាន។ ការដែលដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នាកំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូន ដូច្នេះគប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី ស្របតាមមាត្រា ១០៣៧-១ នៃក្រមរដ្ឋប្បវេណី។

២.៣.ដើម្បីផលប្រយោជន៍កូនគប្បីអនុញ្ញាតឱ្យភាគីឪពុក ដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីម្តាយដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីឪពុកដែលពុំមានអំណាចមេបាក្នុងការទៅសួរសុខទុក្ខកូន។

**៣.ស្តីអំពី ការទាមទារសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន**

ដើមចោទសុំឱ្យចុងចម្លើយបង់ប្រាក់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ ថែរក្សាកូន ក្នុងមួយខែ ចំនួន ២០០.០០០ (ម្ភៃម៉ឺន) រៀល លើកូន១នាក់ឈ្មោះ [redacted] វ៉ានុតផៃ ភេទប្រុស កើតថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ រហូតកូនមាននីតិភាព។ ចំណែកឯចុងចម្លើយ ក៏បានយល់ព្រមតាម

ការទាមទាររបស់ដើមចោទដែរនោះ ដូច្នេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី ដោយបង្គាប់ឱ្យចុងចម្លើយបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ឱ្យទៅដើមចោទ ក្នុងមួយខែ ចំនួន ២០០.០០០ (ម្ភៃម៉ឺន) រៀល ជារៀងរាល់ខែ រហូតដល់កូនមានវ័យនីតិភាព ស្របតាមមាត្រា ១០៤០-២ នៃក្រមរដ្ឋប្បវេណី។

**៤.ស្តីអំពី បន្ទុកនៃប្រាក់ប្រដាប់ក្តី**

ដើមចោទបានអះអាងថា ខ្លួនសុំទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ហើយប្រាក់ប្រដាប់ក្តីនេះដើមចោទក៏បានបង់រួចហើយដែរ ដូច្នេះគប្បីឱ្យដើមចោទជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ស្របតាមមាត្រា ៦៤-២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សេចក្តីសម្រេចបញ្ចប់</u>

**១-លែងលះ** ដើមចោទឈ្មោះ [redacted] ស្រីតូច និង ចុងចម្លើយឈ្មោះ [redacted]៉ាន់នី។

២-កំណត់ថា: ដើមចោទឈ្មោះ [redacted] ស្រីតូច ជាអ្នកមានអំណាចមេបាលើកូនចំនួន១ (មួយ)នាក់ឈ្មោះ [redacted]៉ានុតថៃ ភេទប្រុស កើតថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤។

ភាគីឪពុកដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីម្តាយដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីឪពុក ក្នុងការទៅសួរសុខទុក្ខកូន។

៣-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ៉ានី បង់ប្រាក់សោហ៊ុយចាំបាច់ សម្រាប់ចិញ្ចឹម បីបាច់ថែរក្សាកូន ក្នុងមួយខែ ចំនួន ២០០.០០០(ម្ភៃម៉ឺន)រៀល ជារៀងរាល់ខែ រហូតដល់កូនដល់នីតិភាព ឱ្យទៅដើមចោទឈ្មោះ [redacted] ស្រីតូច។

៤-ដើមចោទឈ្មោះ [redacted] ស្រីតូច ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ វេលារសៀល និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ វេលា រសៀល។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះតាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខានិងត្រា: [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៣កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សៀមរាប ,ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner